សំរេច

ប្រការ ១ : ត្រូវបានផ្ទេរសិទ្ធិជូន ឯកឧត្តម ម៉ុម ជឹមហ៊ុយ រដ្ឋលេខាធិការ នៃក្រសួង អប់រំ យុវជន និង កីឡា ជំនួស ឯកឧត្តម ម៉ុក ម៉ារ៉េត រដ្ឋលេខាធិការ គ្រប់គ្រង បរិដ្ឋាន ដែលជាប់អញ្ជើញទៅបំពេញបេសកម្មនៅ ប្រទេសកាណាដា ចំនួន ១០ ថ្ងៃ ចាប់ ពីថ្ងៃទី ១៤ ដល់ ២៤ ខែ មិថុនា ឆ្នាំ ១៩៩៤ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីរដ្ឋលេខាធិការ គ្រប់ ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃ ឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

*រាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ ១៩៩៤*

# សេចក្តីសំរេច លេខ ៦៥ សសរ

## ស្តីពីការលុបនិតិវិធី និង បែបបទចាស់នៃការនាំឈើចេញ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-យោងសភាពការណ៍យោធា - សន្តិសុខបច្ចុប្បន្ន

-យោងតំរូវការ ជាបន្ទាន់ក្នុងការកសាង និង ពង្រឹងកំលាំងនៃកងយោធពល ខេមរភូមិន្ទ

-បានឃើញសេចក្តីជូនដំណឹងលេខ ១៦៥ សជណ.សរ ចុះថ្ងៃទី ២៩-០១-១៩៩៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តី ពីការបញ្ឈប់ការកាប់ និង ការនាំចេញឈើ មូល ឈើអារ នៅដំណាច់ខែ មិនា ឆ្នាំ ១៩៩៤ ។

-បានឃើញសេចក្តីជូនដំណឹងលេខ ៩៣៣ សជណ.សរ ចុះថ្ងៃទី ២០-១២-១៩៩៣ ស្តីពីការប្រគល់ជូនក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និង ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោះស្រាយលក់ឈើមូល ។

**សំរេច**

**ប្រការ ១** : លុបនិតិវិធី និង បែបបទនៃការនាំឈើចេញ ដែលបានកំណត់កន្លងមក ។

**ប្រការ ២** : កំណត់និតិវិធី និង បែបបទថ្មីនៃការសុំអនុញ្ញាតនាំឈើចេញ មានដូច ខាងក្រោមនេះ :

- រាល់សំណើ សុំនាំឈើចេញ ត្រូវតែមានការយល់ព្រម អនុញ្ញាតពីនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ ផ្ទាល់ ។

-ចំពោះឈើដែលបានកាប់រួចហើយ នឹង មានលិខិតអនុញ្ញាតពីក្រសួងមានសមត្ថកិច្ចកន្លងមក តែពុំទាន់បាននាំចេញ ក្រុមហ៊ុន ឬ អតិថិជន ជាម្ចាស់ឈើ ត្រូវសុំការអនុញ្ញាតជាថ្មីពីនាយករដ្ឋមន្ត្រីទី១ និង ទី ២ តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣** : សហរដ្ឋមន្ត្រីទទួល បន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |